With the support of the
UNESCO Global Media Defence Fund (GMDF)

# សេចក្តីប្រកាសព័ត៌មាន

## សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) ចាប់ផ្តើមគម្រោងថ្មីដើម្បីពង្រឹងសុវត្ថិភាព ផ្នែកផ្លូវច្បាប់ និងផ្នែកផ្លូវចិត្តសម្រាប់អ្នកសារព័ត៌មានបរិស្ថាន

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ —សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជាចាប់ផ្តើមអនុវត្តគម្រោងថ្មីមួយដែលមានឈ្មោះថា «**ពង្រឹងសិទ្ធិអំណាចអ្នកសារព័ត៌មានបរិស្ថាន**» ដែលមានគោលបំណងលើកកម្ពស់ដល់អ្នកសារព័ត៌មានបរិស្ថានដែលកាន់តែប្រឈមនឹងការគំរាមកំហែងផ្សេងៗ។

របាយការណ៍ស្តីអំពីស្ថានភាពរបស់អ្នកសារព័ត៌មានក្នុងឆ្នាំ២០២៤របស់ខេមបូចាបានបង្ហាញថា ៣៩% នៃករណីយាយីទាំងអស់លើអ្នកសារព័ត៌មាន( សរុប៤១ករណី ) ដែលត្រូវបានកត់ត្រា គឺជាការយាយីលើអ្នកសារព័ត៌មានបរិស្ថាន ដែលនេះឆ្លុះបញ្ចាំងពីភាពចាំបាច់ ក្នុងការបង្កើនការការពារទាំងផ្នែកផ្លូវច្បាប់ និង ផ្នែកសុខុមាលភាពផ្លូវចិត្តទៅដល់អ្នកសារព័ត៌មានទាំងនោះ។

ដើម្បីធានាថា អ្នកសារព័ត៌មានបរិស្ថានដែលប្រឈមទៅនឹងការប្រើអំពើហិង្សា ឬបញ្ហាប្រឈមផ្នែកផ្លូវច្បាប់ពាក់ព័ន្ធនឹងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន  អាចទទួលបានសេវាប្រឹក្សាផ្នែកផ្លូវច្បាប់ ទទួលបានមេធាវីក្នុងការការពារក្តីនៅតុលាការ និង ការប្រឹក្សាផ្នែកសុខុមាលភាពផ្លូវចិត្តបានឆាប់រហ័ស គម្រោងដែលមានរយៈពេល១០ខែនេះ នឹងផ្តល់ជូនដល់អ្នកសារព័ត៌មានបរិស្ថានដែលរាយការណ៍ក្នុងប្រទេសកម្ពុជា នូវការគាំទ្រផ្នែកផ្លូវច្បាប់ និងផ្នែកផ្លូវចិត្តពីអ្នកជំនាញ ដោយមិនគិតកម្រៃ និងមានការគិតគូរអំពីយេនឌ័រ ។ ជំនួយនេះនឹងជំរុញការការពារអ្នកសារព័ត៌មានបង្កើនសុវត្ថិភាពដោយពិចារណាអំពីចរិតលក្ខណៈនៃការគំរាមកំហែងផ្អែកលើយេនឌ័រ និងពង្រឹងភាពធន់របស់ពួកគេ។

នាយកប្រតិបត្តិនៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា( ខេមបូចា ) លោក ណុប វី មានប្រសាសន៍ថា៖

**«អ្នកសារព័ត៌មានបរិស្ថានក្នុងប្រទេសកម្ពុជាកំពុងបំពេញការងារដោយរងការគំរាមកំហែងទាំងផ្នែកផ្លូវច្បាប់ ទាំងផ្នែករូបរាងកាយកាន់តែច្រើនឡើងដោយគ្រាន់តែពួកគេរាយការណ៍ព័ត៌មានអំពីបញ្ហាដែលកើតមានទៅដល់សាធារណជន។ តាមរយៈគម្រោងនេះយើងមានគោលបំណងធានាថាពួកគេមិននៅឯកាឡើយ។ ដោយផ្តល់នូវសេវាគាំទ្រផ្នែកផ្លូវច្បាប់និងសេវាប្រឹក្សាផ្នែកផ្លូវចិត្តនេះ យើងសង្ឃឹមថានឹងអាចពង្រឹងភាពធន់របស់អ្នកសារព័ត៌មានបរិស្ថាន និងបង្កើតឲ្យមានលំហសុវត្ថិភាព សម្រាប់ពួកគេក្នុងការបន្តបំពេញការងារដ៏សំខាន់នេះ។ វាមិនត្រឹមតែជាការការពារអ្នកសារព័ត៌មានប៉ុណ្ណោះទេ តែវាក៏ជាការការពារសិទ្ធិទទួលបានព័ត៌មានរបស់សាធារណជនផងដែរ**»។

គម្រោងនេះទទួលបានការគាំទ្រពីមូលនិធិសកលដើម្បីការពារប្រព័ន្ធផ្សព្វផ្សាយ ( Global Media Defence Fund ) ដែលគ្រប់គ្រងចាត់ចែងដោយអង្គការយូណេស្កូ។

With the support of the
UNESCO Global Media Defence Fund (GMDF)

មូលនិធិសកលដើម្បីការពារប្រព័ន្ធផ្សព្វផ្សាយ (Global Media Defence Fund) គឺជាមូលនិធិពហុដៃគូរបស់អង្គការយូណេស្កូដែលបានបង្កើតឡើងនៅក្នុងក្របខណ្ឌនៃយុទ្ធនាការសកលដើម្បីសេរីភាពសារព័ត៌មាន ហើយស្ថិតនៅក្រោមឆ័ត្រនៃផែនការសកម្មភាពរបស់អង្គការសហប្រជាជាតិស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាននិងបញ្ហានិទណ្ឌភាព។ វាត្រូវបានបង្កើតឡើងក្នុងគោលបំណងបង្កើនសេរីភាពសារព័ត៌មាន និងពង្រឹងការទទួលបានជំនួយផ្លូវច្បាប់ពីអ្នកជំនាញ និងមានការគិតគូរដល់បញ្ហាយេនឌ័រ ៕

សម្រាប់ការផ្តល់បទសម្ភាស សូមទាក់ទង៖

លោក ណុប វី នាយកប្រតិបត្តិរបស់ខេមបូចា
អ៊ីមែល៖ ed@camboja.net
លេខទូរសព្ទ៖ 012 519 261

សម្រាប់សំណួរទូទៅ សូមទាក់ទង៖

កញ្ញា ហុក លីកា ជំនួយការផ្នែកទំនាក់ទំនង និងសមាជិកភាព
អ៊ីមែល៖ communications@camboja.net
លេខទូរសព្ទ៖ 098 625 711